**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

# សុន្ទរកថា
## ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
## ថ្លែងក្នុងឱកាសបើកកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី២ ឆ្នាំ២០២៣
## នៅសណ្ឋាគារឯករាជ្យ ខេត្តព្រះសីហនុ ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៣

- *សូមគោរពអង្គពិធីទាំងមូល*
- *ឯកឧត្តម លោកជំទាវ អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍*
- *ឯកឧត្តម លោកជំទាវ ប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង រដ្ឋលេខាធិការដ្ឋាន រាជធានី ខេត្ត និងកាកបាទក្រហមកម្ពុជា*
- *ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិជាទីរាប់អាន!*

ខ្ញុំពិតជាមានកិត្តិយស និងសេចក្តីសោមនស្សរីករាយក្រៃលែងដោយបានមកធ្វើជាអធិបតីដឹកនាំ "**កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី២ ឆ្នាំ២០២៣**"នាពេលនេះ។ តាងនាមអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅបំផុត និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ដែលបានយកពេលវេលាដ៏មានតម្លៃចូលរួមក្នុងកិច្ចប្រជុំពេញអង្គ លើកទី២របស់យើង។

ជាមួយគ្នានេះ ខ្ញុំសូមថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ ដែលបានខិតខំប្រឹងប្រែង និងសហការជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្នុងការជំរុញ និងចូលរួមអនុវត្តលិខិតលេខ ២១៣សជណ.សស ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ស្តីពីវិធានការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ រហូតទទួលបានលទ្ធផលជាវិជ្ជមាន។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា!*

ក្នុងគោលបំណងលុបបំបាត់អេដស៍នៅឆ្នាំ២០២៥ និងឈានឆ្ពោះទៅកាន់ចីរភាពក្នុងការឆ្លើយតបនាពេលខាងមុខ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បាននិងកំពុងដឹកនាំតាក់តែងគោលនយោបាយជាតិលុបបំបាត់ជំងឺអេដស៍នៅឆ្នាំ២០២៥ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨។ គោលនយោបាយនេះនឹងត្រូវដាក់ចេញដើម្បីធានាថា មេរោគអេដស៍នឹងមិនរីករាលដាលបង្កជាគ្រោះថ្នាក់ដល់សុខភាពសាធារណៈផ្សេងទៀត នៅពេលដែលកម្ពុជាឈប់ទទួលហិរញ្ញវត្ថុពីប្រភពខាងក្រៅ។ គោលនយោបាយ នេះរួមមាន៧ចំណុចដូចខាងក្រោម ៖

១) គោលនយោបាយទី១ ៖ ពង្រឹងប្រព័ន្ធជាតិឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍
២) គោលនយោបាយទី២ ៖ ពន្លឿនអត្រាគ្របដណ្តប់កម្មវិធីបង្ការឱ្យបានលើសពី៩៥%
៣) គោលនយោបាយទី៣ ៖ ពង្រីក ពង្រឹង និងពន្លឿនកម្មវិធីបង្ការ
៤) គោលនយោបាយទី៤ ៖ ពង្រីក ពង្រឹង និងពន្លឿនកម្មវិធីគាំពារសង្គម
៥) គោលនយោបាយទី៥ ៖ បញ្ចប់ការរើសអើង និងមាក់ងាយ
៦) គោលនយោបាយទី៦ ៖ ចលនាធនធាន
៧) គោលនយោបាយទី៧ ៖ ពង្រឹងប្រសិទ្ធភាពប្រព័ន្ធតាមដាន និងវាយតម្លៃជាតិ។

យើងរំពឹងថាគោលនយោបាយខាងលើអាចនឹងអនុម័ត នៅដើមនីតិកាលទី៧នៃរដ្ឋសភានេះ។ ជាមួយគ្នានេះ យើងក៏បានបញ្ចប់រួចហើយនូវសេចក្តីព្រាង ផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ លើកទី៦ ឆ្នាំ២០២៤-២០២៨ ដែលជាសមិទ្ធផលថ្មីមួយទៀតកើតចេញពីកិច្ចខិតខំប្រឹងប្រែងរួមគ្នា។ ផែនការយុទ្ធសាស្ត្រជាតិ លើកទី៦ ផ្តោតលើគោលបំណងធំៗចំនួន ៤ដូចខាងក្រោម ៖

១) ផ្តល់នូវការការពារ ការព្យាបាល ការថែទាំ និងការគាំទ្រទូលំទូលាយ និងមានប្រសិទ្ធភាព តាមរយៈការអនុវត្តវិធីសាស្ត្រពហុវិស័យទូលំទូលាយដែលមានការសម្របសម្រួលបានល្អ
២) ធ្វើឱ្យប្រសើរឡើងនូវសុខុមាលភាពនៃប្រជាជនគន្លឹះ និងអ្នកផ្ទុកមេរោគអេដស៍ និងបង្កើតបរិយាកាសអំណោយផល សម្រាប់ពួកគាត់ អាចទទួលបានសេវាអេដស៍ ប្រកបដោយប្រសិទ្ធភាព
៣) ធានានូវនិរន្តរភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ថ្នាក់ជាតិ ដោយបង្កើនការវិនិយោគក្នុងស្រុក និងការពង្រឹងប្រព័ន្ធប្រទេស (Country system) ដែលគ្រប់គ្រង សម្របសម្រួល និងតាមដានការឆ្លើយតបមេរោគអេដស៍
៤) កសាងសមត្ថភាពស្ថាប័ន សហគមន៍ និងបុគ្គល ដើម្បីពង្រឹងការឆ្លើយតបដែលដឹកនាំសហគមន៍ និងកែលម្អការរួមបញ្ចូលមេរោគអេដស៍ក្នុងវិស័យសុខាភិបាល និងវិស័យមិនមែនសុខភាព។

ឆ្លៀតក្នុងឱកាសនេះ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សូមវាយតម្លៃខ្ពស់ចំពោះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានជួយគាំទ្រគោលនយោបាយជាតិរបស់យើងដោយបានដាក់ចេញនូវនីតិវិធីជាតិសម្រាប់ប្រើប្រាស់ថវិការដ្ឋនៅថ្នាក់ក្រោមជាតិ និងផ្តល់ថវិកាសម្រាប់ការងារអេដស៍ដល់ក្រសួង និងស្ថាប័នពាក់ព័ន្ធ ទោះជាក្នុងកម្រិតណាក៏ដោយ ដែលនេះជាកត្តាមិនអាចខ្វះបានដើម្បីសម្រេចគោលដៅលុបបំបាត់ជំងឺអេដស៍នៅឆ្នាំ២០២៥។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា!*

កិច្ចប្រជុំពេញអង្គលើកទី២របស់យើង ធ្វើឡើងដើម្បីពិនិត្យមើលរួមគ្នានូវវឌ្ឍនភាព សមិទ្ធផល និងប្រសិទ្ធភាពក្នុងការប្រយុទ្ធនឹងជំងឺអេដស៍ សម្រាប់រយៈពេល៦ខែចុងឆ្នាំ២០២៣។ ជាមួយគ្នានេះ

យើងនឹងធ្វើការពិភាក្សា និងប្រមូលធាតុចូល រួមជាមួយនឹងអនុសាសន៍ដែលបានលើកឡើង តាមរយៈការចូលរួមរបស់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី នាងកញ្ញាដែលមានវត្តមានក្នុងពេលនេះផងដែរ។

តាមរបៀបវារៈកិច្ចប្រជុំ យើងនឹងមានបទបង្ហាញចំនួនពីរដែលរួមមាន ៖ ១) បទបង្ហាញស្តីពីវឌ្ឍនភាពនៃការអនុវត្តសេចក្តីសម្រេចចិត្តកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី ១ ឆ្នាំ២០២៣ ដោយឯកឧត្តមបណ្ឌិត ឈឹម យិនដារ៉េត អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និង២) បទបង្ហាញស្តីពីសេចក្តីព្រាងផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយនិងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៦ និងសេចក្តីព្រាងគោលការណ៍ណែនាំស្តីពីយន្តការរាយការណ៍ និងឆ្លើយតបនឹងការមាក់ងាយនិងការរើសអើង ដោយឯកឧត្តមវេជ្ជបណ្ឌិត ទា ផលា អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

មុននឹងបញ្ចប់ យើងនឹងពិភាក្សា និងអនុម័តសេចក្តីសម្រេចចិត្ត កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី២ ឆ្នាំ២០២៣ផងដែរ។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា!*

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមទាញអារម្មណ៍កិច្ចប្រជុំពេញអង្គថា យើងបាននិងកំពុងតែធ្វើដំណើររួមគ្នាប្រកបដោយទស្សនវិស័យច្បាស់លាស់ក្នុងក្តីសង្ឃឹមពិតប្រាកដ ឆ្ពោះទៅរកការលុបបំបាត់ជំងឺអេដស៍ក្នុងពេលដ៏ខ្លីខាងមុខ។ ជាមួយគ្នានេះ យើងអាចធានាបាននូវចីរភាពនៃការឆ្លើយតបជាពហុវិស័យ ពីគ្រប់ស្ថាប័នជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល វិស័យឯកជន ជាពិសេសបណ្តាញអ្នកផ្ទុកមេរោគអេដស៍។ យើងទាំងអស់គ្នាបង្កើតបាននូវស្ថាប័នដឹកនាំគ្រប់គ្រងនិងសម្របសម្រួលតែមួយទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ជាពិសេសយើងមានផែនការយុទ្ធសាស្ត្រជាតិតែមួយ មានប្រព័ន្ធតាមដាន និងវាយតម្លៃ ជាតិតែមួយប្រកបដោយប្រសិទ្ធភាពខ្ពស់។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា!*

ខ្ញុំមានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា លទ្ធផលដែលទទួលបានពីកិច្ចប្រជុំនេះ ពិតជាមានសារៈសំខាន់ ដែលនឹងផ្តល់ទៅដល់ក្រុមការងារបច្ចេកទេស អាចយកទៅប្រើប្រាស់ក្នុងការបន្តអនុវត្តការងារឆ្លើយតបទៅនឹងការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ នៅក្នុងពេលខាងមុខ ឱ្យស្របទៅតាមអនុសាសន៍ ដែលនឹងផ្តល់ជូនក្នុងកិច្ចប្រជុំពេញអង្គ នាពេលបន្តិចទៀតនេះ។

ជាទីបញ្ចប់នេះ ខ្ញុំសូមប្រសិទ្ធពរជូនឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ សូមមានសុខភាពល្អ កម្លាំងមាំមួន និងប្រាជ្ញាវាងវៃ ដើម្បីចូលរួមពិភាក្សាឱ្យទទួលបានជោគជ័យទៅតាមកម្មវត្ថុដែលបានគ្រោងទុក។

ខ្ញុំសូមប្រកាសបើក “**កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី២ ឆ្នាំ ២០២៣**” ចាប់ពីពេលនេះតទៅ។

សូមអរគុណ!